**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

***********

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**លេខ ៖** ២៤ កបធ

# បទបញ្ជា

## ស្ដីពីនីតិវិធីដែលត្រូវអនុវត្ត នៅមុខក្រុមប្រឹក្សាធម្មនុញ្ញ

## ក្រុមប្រឹក្សាធម្មនុញ្ញ

*******

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានប្រកាសអោយប្រើ តាមព្រះរាជក្រមលេខ ជស-រកម-០៤៩៨-០៦ ចុះថ្ងៃទី ១៩ ខែមិនា ឆ្នាំ១៩៩៨
- បានឃើញបទបញ្ជាផ្ទៃក្នុង នៃ ក្រុមប្រឹក្សាធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ១៩៩៨
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ-បក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៨ ស្ដីពីការបង្កើតអគ្គលេខា-ធិការដ្ឋាន នៃក្រុមប្រឹក្សាធម្មនុញ្ញ ។

## <u>សំរេច</u>

## <u>ជំពូកទី១</u>

## នីតិវិធីទាក់ទងនឹងការបកស្រាយរដ្ឋធម្មនុញ្ញ បកស្រាយច្បាប់ និង សេចក្ដីសំរេច នៃស្ថាប័ននានារបស់រដ្ឋ

**<u>ប្រការ១</u>** ៖ អនុលោមតាមមាត្រា ១៥,១៦,១៧,១៨ និងមាត្រា១៩ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុម- ប្រឹក្សាធម្មនុញ្ញ ក្រោយពីបានទទួលសំនើពីព្រះមហាក្សត្រ ពីប្រធានរដ្ឋសភា ពីនាយករដ្ឋមន្ត្រី ពីតំណាងរាស្ត្រ មួយភាគដប់ ពីតុលាការ ពីប្រជារាស្ត្រ តាមរយៈប្រធានរដ្ឋសភា ឬតំណាងរាស្ត្រមួយភាគដប់ ឬ ពីតុលាការ- កំពូល ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវចាត់អោយចុះបញ្ជីនៅអគ្គលេខាធិការដ្ឋាន ។

**<u>ប្រការ២</u>** ៖ រយៈពេលដោះស្រាយត្រូវចាប់រាប់តាំងពីថ្ងៃចុះបញ្ជីនេះ ហើយពេលវេលាដោះស្រាយត្រូវធ្វើតាមការកំណត់ ក្នុងច្បាប់ ។

**ប្រការ៣** ៖ ក្រោយពេលចុះបញ្ជីរួច ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវបញ្ជូនសំនើទាំងនោះទៅក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីពិនិត្យ ។ របាយការណ៍របស់ក្រុម នៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវដាក់ជូនសម័យប្រជុំបឋម ដើម្បីចុះសៀវភៅដាក់រឿងជនុំជំរះ ។

**ប្រការ៤** ៖ ក្រុមនិមួយៗ នៃក្រុមប្រឹក្សាធម្មនុញ្ញ មានសមាជិក ៣រូប ដែលមួយរូបជាសមាជិកតែងតាំងដោយ ព្រះមហាក្សត្រ មួយរូប ជាសមាជិកតែងតាំង ដោយឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម និងមួយរូបទៀត ជាសមាជិកជ្រើសតាំង ដោយរដ្ឋសភា ។

សមាជិកក្នុងក្រុមទាំងបីនេះត្រូវជ្រើសរើសដោយវិធីចាប់ឆ្នោត ក្រោមអធិបតីភាពនៃប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។ សមាជិករាយការណ៍ត្រូវតែងតាំងដោយប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។

**ប្រការ៥** ៖ ក្នុងប្រតិបត្តិការងារ សមាជិករាយការណ៍ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដោយគ្រាន់តែជូនពត៌មានទៅប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។

**ប្រការ៦** ៖ ទោះក្នុងករណីណាក៏ដោយសមាជិករាយការណ៍ ត្រូវតែរាយការណ៍ជូនសម័យប្រជុំបឋម ដើម្បីចុះក្នុងសៀវភៅដាក់រឿងជំនុំជំរះ ។ របាយការណ៍នេះត្រូវដាក់ជូនអង្គប្រជុំពេញអង្គ ដើម្បីពិភាក្សា និងសំរេចជាស្ថាពរ ។

**ប្រការ៧** ៖ ចំពោះគ្រប់សំនើអោយពិនិត្យទាំងអស់ខាងលើ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសរេចក្នុងពេលវេលាមួយដែលមានកំណត់ក្នុងច្បាប់ និងតាមមតិភាគច្រើនដាច់ខាត នៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល (៥សំឡេងយ៉ាងតិច) ។

## **ជំពូកទី ២**

## **នីតិវិធីអំពីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ**

**ប្រការ៨** ៖ អនុលោមតាមមាត្រា ២៥,២៦ និងមាត្រា ២៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ ក្រុមប្រឹក្សាធម្មនុញ្ញ វិវាទកម្មដែលទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវសំរេចដោយ ក្រុមប្រឹក្សាធម្មនុញ្ញ ។

**ប្រការ៩** ៖ បុគ្គលណា ឬ គណបក្សនយោបាយណាដែលមិនសុខចិត្ត នឹងការមិនព្រមចុះបញ្ជីគណបក្សនយោបាយ ដោយក្រសួងមហាផ្ទៃ ឬ មិនសុខចិត្ត និងសេចក្តីសំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ មិនសុខចិត្តនឹងលទ្ធផលនៃការបោះឆ្នោត ត្រូវធ្វើពាក្យប្តឹងជាលាយល័ក្ខអក្សរជូនទៅក្រុមប្រឹក្សាធម្មនុញ្ញ ។ ពាក្យសុំនេះត្រូវញ្ជាក់ ៖

១- ឈ្មោះបុគ្គល ឬ ឈ្មោះគណបក្សនយោបាយ ដែលជាអ្នកប្តឹងតវ៉ា

២- ឋានៈតាមផ្លូវច្បាប់របស់អ្នកប្តឹងតវ៉ា

៣- ឈ្មោះមណ្ឌលបោះឆ្នោត ដែលមានការប្តឹងតវ៉ា

៤- ឈ្មោះបុគ្គល ឬ គណបក្សនយោបាយ ដែលត្រូវបានគេប្រកាសថាជាប់ឆ្នោតហើយ ដែលគេប្តឹងតវ៉ា

៥- គ្រប់ឯកសារ ឬ ភស្តុតាងសំរាប់គាំទ្រការសុំបដិសេធ

៦- អាស័យដ្ឋានអ្នកប្តឹងតវ៉ា

ក្រុមប្រឹក្សាធម្មនុញ្ញ ផ្អែកតាមឆន្ទានុសិទ្ធិរបស់ខ្លួនអាចទុកពេល ៥ថ្ងៃ អោយបុគ្គល ឬ គណបក្សនយោបាយ ដែលជា អ្នកប្តឹង ដើម្បីផ្តល់ភស្តុតាង។

ក្រុមប្រឹក្សាធម្មនុញ្ញ អាចសំរេចមិនធ្វើការស៊ើបអង្កេតលើបណ្តឹងណាមួយ បើបណ្តឹងនោះមិនបំពេញលក្ខខណ្ឌ កំណត់ក្នុងប្រការនេះ។

**ប្រការ១០** : ដើម្បីស្រាវជ្រាវស៊ើបអង្កេតអំពីវិវាទកម្មទាក់ទងទៅនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ក្រុមប្រឹក្សា-ធម្មនុញ្ញ ត្រូវអនុវត្តតាមប្រការ ៣,៤,៥ និងប្រការ ៦ នៃបទបញ្ជានេះ នឹងមាត្រា ៣០,៣១,៣២,៣៣ និង មាត្រា ៣៤ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

**ប្រការ១១** : ក្រោយពីក្រុមនិមួយៗ បានពិភាក្សាចប់សព្វគ្រប់ហើយ ទោះបីការពិភាក្សានោះពុំបានចុះសំរុងគ្នាក៏ដោយក៏ ត្រូវធ្វើរបាយការណ៍មួយដាក់ជូនសម័យប្រជុំបឋមដើម្បីចុះក្នុងសៀវភៅដាក់រឿងជំនុំជំរះ។ របាយការណ៍ នេះត្រូវដាក់ជូនអង្គប្រជុំពេញអង្គដើម្បីពិភាក្សាសម្រេច។

**ប្រការ១២** : ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបើកសវនាការជាសាធារណៈ ដើម្បីពិនិត្យនិងសំរេចក្នុងរយៈពេលដែលមានកំណត់ ក្នុងច្បាប់។

**ប្រការ១៣** : អង្គប្រជុំក្រុមប្រឹក្សាធម្មនុញ្ញដែលពិភាក្សាទៅលើរបាយការណ៍របស់ក្រុមត្រូវចាត់តាំងអោយធ្វើកំណត់ហេតុ តាមករណីរឿងនិមួយៗ ។ ការសំរេចរបស់អង្គប្រជុំព្រមទាំងកំណត់ហេតុ ត្រូវចុះក្នុងសៀវភៅកំណត់ហេតុ ជំនុំជំរះ។

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបញ្ជាក់អំពីហេតុផល។

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសំរេចតាមមតិភាគច្រើនដាច់ខាត នៃសមាជិកទាំងមូល (៥សំឡេង យ៉ាងតិច)។ សេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា។

**ប្រការ១៤** : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីបទបញ្ជានេះ ត្រូវទុកជានិរាករណ៍

**ប្រការ១៥** : សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការ នៃក្រុមប្រឹក្សាធម្មនុញ្ញត្រូវទទួលអនុវត្តបទបញ្ជានេះចាប់ពី ថ្ងៃចុះហត្ថលេខាតទៅ។

**ភ្នំពេញ,ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ១៩៩៨**

**ជ. ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ចាន់ សុក